**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៤៣ សជណ.កប៨

# សេចក្តីថ្លែងហេតុ
# អំពី
# សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង

អនុសញ្ញាស្តីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ត្រូវបានរៀបចំឡើងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដោយបានឆ្លងកាត់កិច្ចប្រជុំពិនិត្យនិងពិភាក្សាយ៉ាងល្អិតល្អន់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ស្របតាមច្បាប់ជាតិនៃភាគីនីមួយៗនិងតាមច្បាប់អន្តរជាតិ ដែលកិច្ចប្រជុំទាំងនេះបានប្រព្រឹត្តទៅលើកទី១ នៅថ្ងៃទី១០ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ និងលើកទី២ នៅខែមេសា ឆ្នាំ២០១៥ នៅរដ្ឋធានីប៉ារីសនៃសាធារណរដ្ឋបារាំង។ ភាគីទាំងពីរបានឯកភាពគ្នានិងបានចុះហត្ថលេខាជាផ្លូវការលើអនុសញ្ញានេះនៅរដ្ឋធានីប៉ារីសនៃសាធារណរដ្ឋបារាំង នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥។

អនុសញ្ញានេះ មានគោលបំណងដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរក្នុងការប្រឆាំងឧក្រិដ្ឋកម្មដោយគោរពតាមគោលការណ៍រដ្ឋធម្មនុញ្ញរៀងៗខ្លួន អធិបតេយ្យភាព សមភាព និងផលប្រយោជន៍គ្នាទៅវិញទៅមក ព្រមទាំងជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការរួមចំណែកយ៉ាងសកម្មក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន រួមមានការជួញដូរមនុស្សពិសេសស្ត្រីនិងកុមារ ការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងអំពើពុករលួយ។

អនុសញ្ញានេះផ្តល់សារៈសំខាន់និងអត្ថប្រយោជន៍ដល់គូភាគីក្នុងការបង្កើតឱ្យមាននូវក្របខ័ណ្ឌច្បាប់ដើម្បីស្វែងរកជនល្មើសដែលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអន្តរជាតិក្នុងវិស័យព្រហ្មទណ្ឌ។

អនុសញ្ញាស្តីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងមាន ២៥មាត្រា ដែលមានខ្លឹមសារសង្ខេបសំខាន់ៗដូចខាងក្រោម៖

- មាត្រា១ កំណត់អំពីកាតព្វកិច្ចធ្វើបត្យាប័ន
- មាត្រា២ កំណត់អំពីបទល្មើសដែលអាចធ្វើបត្យាប័នបាន
- មាត្រា៣ កំណត់អំពីមូលហេតុដាច់ខាតនៃការបដិសេធបត្យាប័ន
- មាត្រា៤ កំណត់អំពីមូលហេតុមិនដាច់ខាតនៃការបដិសេធបត្យាប័ន
- មាត្រា៥ កំណត់អំពីទោសប្រហារជីវិត

- មាត្រា៦ កំណត់អំពីការធ្វើបត្យាប័នចំពោះពលរដ្ឋសាមី
- មាត្រា៧ កំណត់អំពីនីតិវិធី
- មាត្រា៨ កំណត់អំពីការបញ្ជូនសំណើនិងឯកសារពាក់ព័ន្ធ
- មាត្រា៩ កំណត់អំពីព័ត៌មានបន្ថែម
- មាត្រា១០ កំណត់អំពីភាសាដែលប្រើប្រាស់និងសុពលភាពនៃឯកសារ
- មាត្រា១១ កំណត់អំពីសេចក្ដីសម្រេចនិងការប្រគល់ខ្លួន
- មាត្រា១២ កំណត់អំពីការលើកពេលនៃការប្រគល់ខ្លួននិងការប្រគល់ខ្លួនជាបណ្ដោះអាសន្ន
- មាត្រា១៣ កំណត់អំពីការប្រគល់វត្ថុ
- មាត្រា១៤ កំណត់អំពីវិធានពិសេស
- មាត្រា១៥ កំណត់អំពីការធ្វើបត្យាប័នបន្តទៅរដ្ឋទីបី
- មាត្រា១៦ កំណត់អំពីការយល់ព្រមរបស់បុគ្គលដែលត្រូវបានស្នើសុំធ្វើបត្យាប័ន
- មាត្រា១៧ កំណត់អំពីការចាប់ខ្លួនជាបណ្ដោះអាសន្ន
- មាត្រា១៨ កំណត់អំពីការជូនដំណឹងអំពីលទ្ធផល
- មាត្រា១៩ កំណត់អំពីការឆ្លងកាត់
- មាត្រា២០ កំណត់អំពីករណីពាក្យស្នើសុំបត្យាប័នច្រើនលើបុគ្គលតែម្នាក់
- មាត្រា២១ កំណត់អំពីការចំណាយ
- មាត្រា២២ កំណត់អំពីទំនាក់ទំនងជាមួយសន្ធិសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត
- មាត្រា២៣ កំណត់អំពីការដោះស្រាយវិវាទ
- មាត្រា២៤ កំណត់អំពីការអនុវត្តអនុសញ្ញានៅក្នុងកាល
- មាត្រា២៥ កំណត់អំពីការចូលជាធរមាននិងការបញ្ចប់អនុសញ្ញា។

សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្ដីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ដើម្បីបញ្ជូនទៅសុំការពិនិត្យនិងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិដែលរួមមាន២មាត្រា។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យនិងអនុម័តលើសេចក្ដីព្រាងច្បាប់នេះដោយក្ដីអនុគ្រោះ។

ថ្ងៃសុក្រ ១០រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**